# ការងារអភិវឌ្ឍន៍ ប្រកបដោយច្នៃប្រឌិត និងចីរភាព



ប្រហែលជា ៨៣ភាគរយនៃប្រជាជនកម្ពុជាបានធ្វើការចំណាកស្រុកមិនប្រក្រតីចូលទៅកាន់ប្រទេសថៃ នេះបើយោងតាមការប៉ាន់ស្មានពីការិយាល័យប្រយុទ្ធប្រឆាំងថ្នាំញៀន និងបទឧក្រិដ្ឋរបស់អង្គការសហប្រជាជាតិ(UNODC)នៅឆ្នាំ២០១៣។ ដោយសារតែមានការព្រួយបារម្ភខ្លាំងអំពីលទ្ធភាពនៃកំ ណើនប្រជាជនកម្ពុជា ក្នុងការធ្វើចំណាកស្រុកដោយខុសច្បាប់ទៅកាន់ប្រទេសដទៃទៀត នោះគម្រោងទប់ស្កាត់ការជួញដូរកម្លាំងពលកម្មរបស់អាយស៊ីស៊ី (ទ.ជ.ក) ដែលមានទីតាំងស្ថិតនៅក្នុងខេត្តព្រៃវែង បានសំរេចចិត្តបង្កើតក្រុមឃ្លាំមើល ដើម្បីឃ្លាំមើល និងកំណត់អត្តសញ្ញាណអ្នកជួញដូរមនុស្ស និងឈ្មួញកណ្តាលដែលនៅពីក្រោយការធ្វើចំណាកស្រុកខុសច្បាប់ និងដើម្បីការពារអ្នកភូមិពីការជួញដូរ ក៏ដូចជាការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព។ សមាជិកក្រុមឃ្លាំមើលមួយរូបនៅក្នុងស្រុកព្រះស្តេច បានធ្វើការប្រឈមមុខជាមួយជនសង្ស័យមួយរូបដែលបានមកកាន់ភូមិរបស់គាត់ កាលពីខែមិថុនា ឆ្នាំ២០១៨ ដោយបានធ្វើការបោកប្រាសផ្តល់អាហារូបករណ៍ក្លែងក្លាយទៅកាន់ក្មេងៗ ដែលមានអាយុចន្លោះពី១៣ ទៅ១៥ឆ្នាំ។ នៅពេលដែលសមាជិកក្រុមឃ្លាំមើលបានដឹងអំពីរឿងនេះហើយ គាត់បានសួរទៅកាន់ជនម្នាក់នោះទៀតថា តើគេបាននិយាយគ្នាជាមួយប្រធានភូមិហើយឬនៅ ប៉ុន្តែជនម្នាក់នោះប្រាប់ថាមិនទាន់បាននិយាយជាមួយទេហើយក៏បាននិយាយទៀតថាពួកគេចង់ឲ្យកុមារចូលរួមការប្រជុំនៅក្បែរភូមិផង។ បន្ទាប់មក សមាជិកក្រុមឃ្លាំមើលក៏បានសួរគេបន្ថែមទៀតថា តើកិច្ចប្រជុំនោះធ្វើនៅកន្លែងណា ប៉ុន្តែជនម្នាក់នោះមិនបានឆ្លើយតបទេហើយក៏បានធ្វើការគេចខ្លួនទៅបាត់។

ដើម្បីធ្វើការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកខុសច្បាប់ បច្ចុប្បន្ននេះ ក្រុមឃ្លាំមើលមានចំនួន៣៤ ហើយក្រុមរបស់ពួកគាត់ត្រូវបានបង្កើតឡើងដោយប្រជាជនដែលមានការប្តេជ្ញាចិត្ត និងការលើកទឹកចិត្តខ្ពស់ក្នុងការការពារភូមិរបស់ពួកគាត់។ សមាជិកក្រុមមានដូចជា សមាជិកនៃក្រុមជួយខ្លួនឯងដែលបានបង្កើតឡើងដោយអាយស៊ីស៊ី ចាស់ទុំក្នុងភូមិ គ្រូបង្រៀន និងថ្នាក់ដឹកនាំវត្តអារាម។ ដោយសារតែការប្តេជ្ញាចិត្ត និងការលើកទឹកចិត្តដ៏រឹងមាំរបស់ពួកគេក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ ក្រុមឃ្លាំមើលកំពុងទទួលបាននូវការទទួលស្គាល់ពីសំណាក់មេភូមិ និងពីសហគមន៍របស់ពួកគាត់ចំពោះសកម្មភាពវិជ្ជមានដែលពួកគាត់បានធ្វើ។ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ក្រុមឃ្លាំមើលបានប្រើប្រាស់មធ្យោបាយដូចជា ការបង្ហាញខ្សែវីដេអូពេលរាត្រីអំពីផលប៉ះពាល់នៃការជួញដូរមនុស្ស របៀបស្វែងរកមុខសញ្ញា កំណត់សំគាល់ និងរាយការណ៍ពីករណីជួញដូរមនុស្សទៅដល់អាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើការ អន្តរាគមន៍។ មធ្យោបាយចាំបាច់ទាំងនេះ គឺបានកើតចេញមកពីការសហការយ៉ាងជិតស្និទ្ធជាមួយ គម្រោង ទ.ជ.ក របស់អាយស៊ីស៊ី ដែលធ្វើឲ្យក្រុមរបស់ពួកគាត់ទទួលបាននៅជំនាញ និងចំណេះដឹងក្នុងការអភិវឌ្ឍទស្សនៈវិស័យ បេសកកម្ម និងគុណតម្លៃ តួនាទី និងការទទួលខុសត្រូវ និងការធ្វើផែនការសកម្មភាព។ ពួកគេក៏ទទួលបានការបណ្តុះបណ្តាលសមត្ថភាពពីក្រុមការងាររបស់ គម្រោង ទ.ជ.ក របស់អាយស៊ីស៊ី អំពីរបៀបស្វែងរកមុខសញ្ញា និងកំណត់អត្តសញ្ញាណអ្នកជួញដូរ និងឈ្មួញកណ្តាលដែលនៅពីក្រោយខ្នងនៃការធ្វើចំណាកស្រុកខុសច្បាប់ របៀបសរសេររបាយការណ៍ និងរបៀបរាយការណ៍ករណីជួញដូរទៅកាន់អាជ្ញាធរមូលដ្ឋាន។

សមិទ្ធផលដែលក្រុមឃ្លាំមើលបានសម្រេចកន្លងមក គឺថាពួកគេអាចកំណត់មុខសញ្ញាជនចម្លែកដែលបានចូលមកភូមិរបស់ពួកគេ ដើម្បីធ្វើការឆក់បោកយកកុមារតូចៗតាមរយៈការផ្តល់អំណោយ។ ពួកគេ ក៏បានធ្វើការចែករំលែកនូវអ្វីដែលពួកគេបានរៀនសូត្រពី គម្រោង ទ.ជ.ក របស់អាយស៊ីស៊ី ទៅដល់អ្នកភូមិ សាច់ញាតិ និងអ្នកជិតខាងរបស់ពួកគេ ក៏ដូចជាផ្តល់ប្រឹក្សាយោបល់ អំពីការគួរតែធ្វើចំណាកស្រុកទៅប្រទេសថៃ ឬធ្វើការនៅក្នុងប្រទេសរបស់ខ្លួន។ រហូតមកដល់ពេលនេះ ការយល់ឃើញរបស់ប្រជាជនក្នុងតំបន់មកលើក្រុមឃ្លាំមើល គឺមានភាពវិជ្ជមានជាខ្លាំង ដោយសារតែប្រជាជនបានឃើញពួកគេចូលរួមចំណែក យ៉ាងច្រើនដល់ការការពារសហគមន៍របស់ពួកគេឲ្យគេចផុតពីការជួញដូរ និងការធ្វើចំណាកស្រុកខុសច្បាប់។ ក្រុមឃ្លាំមើល បានធ្វើការស្ម័គ្រចិត្តប្រើប្រាស់ ធនធានផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីធ្វើការការពារសហគមន៍ ហើយធនធានទាំងអស់នោះរាប់បញ្ចូលទាំងការចំណាយថ្លៃទំនាក់ទំនង ថ្លៃធ្វើដំណើរ ពេលវេលា និងការផ្តល់កន្លែងប្រជុំ។ រហូតមកដល់ពេលនេះ គម្រោង ទ.ជ.ក របស់អាយស៊ីស៊ី បានរួមចំណែកយ៉ាងសំខាន់ដល់ការរីកចម្រើនរបស់ក្រុមឃ្លាំមើល។ ទាំងអស់នេះ គឺរួមបញ្ចូលទាំងការជួយផ្តួចផ្តើមបង្កើតក្រុម និងក្នុងការកសាងទស្សនៈវិស័យ បេសកកម្ម និងគុណតម្លៃរបស់ពួកគេ។ គម្រោង ទ.ជ.ក របស់អាយស៊ីស៊ី ក៏បានផ្តល់ឲ្យពួកគេ នូវការបណ្តុះបណ្តាលសមត្ថភាព ជួយពួកគេឲ្យចេះប្រមូលផ្តុំ និងមានភាពសកម្មតាមដានតួនាទី និងការទទួលខុសត្រូវរបស់ពួកគេ និងជួយពួកគេបន្ថែមទៀត ក្នុងការទទួលបាននូវការទទួលស្គាល់ជាផ្លូវការពីសំណាក់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ លើសពីនេះទៀត គម្រោង ទ.ជ.ក របស់អាយស៊ីស៊ី ចង់ឃើញក្រុម ឃ្លាំមើលមាននិរន្តរភាព និងបន្តរក្សាសុវត្ថិភាពដល់សហគមន៍របស់ខ្លួនឲ្យរួចផុតពីការជួញដូរទាំងនេះ។

កាលបរិច្ឆេទ៖ សីហា ២០១៨